អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន

# ក្រុមមេធាវីការពារក្តីខៀវ សំផន និង នួន ជា ត្រូវបានព្រមានចំពោះការប្រព្រឹត្ត កំហុសវិជ្ជាជីវៈ និងត្រូវបានបង្គាប់ឲ្យបង្ហាញខ្លួននៅក្នុងកិច្ចប្រជុំរៀបចំសវនាការ

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចេញនូវការព្រមានជាផ្លូវការមួយអំពីការប្រព្រឹត្តកំហុសវិជ្ជាជីវៈចំពោះក្រុមមេធាវីជាតិ និងអន្តរជាតិរបស់ខៀវ សំផន និងនួន ជា អនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង។

ការព្រមាននេះត្រូវបានចេញបន្ទាប់ពីក្រុមមេធាវីការពារក្តីបានចាកចេញពីបន្ទប់សវនាការនៅអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៤ ហើយក្រោយមកមេធាវីទាំងពីរក្រុមខកខានមិនបានចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៤ ដោយមិនបានបង្ហាញពីហេតុផលនៃអវត្តមានរបស់ពួកគេឡើយ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាអំពើនេះគឺជាការរាំងកិច្ចដំណើរការនីតិវិធី។

ក្រុមមេធាវីការពារក្តីខៀវ សំផន និងនួន ជា ត្រូវបានបង្គាប់ឲ្យបង្ហាញខ្លួននៅក្នុងកិច្ចប្រជុំរៀបចំសវនាការនៅក្នុងបន្ទប់សាលសវនាការធំ**នៅថ្ងៃអង្គារ ទី២៨ ខែតុលា ឆ្នាំ ២០១៤ វេលាម៉ោង ៩ ព្រឹក។ កិច្ចប្រជុំនេះនឹងប្រព្រឹត្តទៅជាអសាធារណៈ** ហើយនេះគឺជាឱកាសដ៏សំខាន់សម្រាប់ក្រុមមេធាវីការពារក្តីខៀវ សំផន ដើម្បីពិភាក្សាអំពីបញ្ហាធនធាននាពេលបច្ចុប្បន្នជាមួយអង្គជំនុំជម្រះសាលាដំបូង។ ភាគីពាក់ព័ន្ធនានាត្រូវបានអញ្ជើញឲ្យលើកមតិយោបល់ទៅលើសំណើរបស់សហព្រះរាជអាជ្ញាដើម្បីចាត់តាំងមេធាវីពីខាងក្រៅដើម្បីធ្វើជាតំណាងផលប្រយោជន៍របស់ជនជាប់ចោទ និងជំរុញកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២។

ដោយបានឃើញពីការវិវឌ្ឍទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលុបចោល នូវកាលបរិច្ឆេទសវនាការដែលគ្រោងចាប់ផ្តើមឡើង នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៤។ កាលបរិច្ឆេទថ្មីនៃដំណើរការសវនាការនឹងត្រូវជម្រាបជូនក្នុងពេលវេលាសមស្របខាងមុខ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក **ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទដៃ៖ +៨៥៥(០)១២ ៤៨៨ ០២៣
ទូរស័ព្ទ៖ +៨៥៥(០)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក៖ olsenl@un.org

លោក **នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖ +៨៥៥(០)១២ ៤៨៨ ១៥៦
ទូរស័ព្ទ៖ +៨៥៥(០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh